## តើត្រូវធ្វើដូចម្តេចដើម្បីក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាព?

*រៀបរៀងដោយ ឡេងឆាយ*

មុនពេលអ្នកអាចរៀនប្រធានបទណាមួយឬជំនាញណាមួយមានប្រសិទ្ធភាព អ្នកត្រូវយល់ដឹងអំពីវិធីដែលអ្នកជ្រើសយកដើម្បីរៀនសូត្រពីវា។អ្នកអាចក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាពម្នាក់ តាមរយៈការប៉ាន់ប្រមាណបែបបទរៀនសូត្ររបស់អ្នកផ្ទាល់ ហើយកំនត់យកនិងប្រើប្រាស់វិធីសមស្របបំផុត អំពីថាតើត្រូវរៀនសូត្រដោយវិធីណា។

### ជំនាញរៀនសូត្រសំខាន់ៗដែលអាចជួយអ្នកអោយក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាពបានរួមមាន៖

- ការធ្វើកំនត់ត្រាផ្ទាល់ខ្លួន
- ស្ទឹងជីវិត ឬទន្លេជីវិត
- វដ្តរៀនសូត្រពីសកម្មភាព
- ការសង្កេតបែបវិជ្ជមាន
- រឿងរ៉ាវផ្លាស់ប្តូរ
- ផែនទីគំនិត
- ការគិតបែបវិភាគ/ស៊ីជំរៅ
- ការបង្កើត និងសួរសំនួរ
- ការស្តាប់ដោយយកចិត្តទុកដាក់
- ការបញ្ជាក់ត្រលប់
- បច្ចេកទេសនៃការអាន
- ការសង្កេត

មានឥរិយាបថចំនួន៦ ដែលគួរប្រកាន់យក ដើម្បីក្លាយជាអ្នករៀនសូត្រប្រកបដោយជោគជ័យ៖

### ១.ការចង់ចេះចង់ដឹង

ខ្ញុំព្យាយាមរកចំលើយដោយខ្លួនឯង ជាជាងរង់ចាំគេប្រាប់។

### ២.មានទំនុកចិត្ត

ខ្ញុំពង្រឹងបន្ថែមលើចំនុចខ្លាំង និងព្យាយាមបំបាត់ចំនុចខ្សោយរបស់ខ្ញុំ។

### ៣.មានការប្តេជ្ញាចិត្ត

ប្រើប្រាស់ពេលវេលា និងថាមពលដើម្បីរៀនសូត្រ ហើយសំរេចគោលដៅរបស់ខ្ញុំមួយជំហានម្តងៗ។

### ៤.ការផ្តោតអារម្មណ៍

ផ្តោតលើការងារបច្ចុប្បន្ន ហើយព្យាយាមបំបាត់នូវការរំខាននានា។

### ៥.មានជំនឿចិត្តខ្ពស់

ខ្ញុំប្រាកដជាអាចធ្វើវាបាន។

### ៦.មានការសរសើរខ្លួនឯង

អបអរសាទរចំពោះជោគជ័យតូចៗរបស់ខ្ញុំ និងជោគជ័យធំៗ។

This learning article shared by Cambodian Learning Facilitators (www.camlefa.org). All rights reserved.